# ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប
# NEC BULLETIN

លេខ ៤ ចេញផ្សាយថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១


# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



## សេចក្តីបំភ្លឺរបស់អ្នកនាំពាក្យ គ.ជ.ប

### ចំពោះការលើកឡើងមិនត្រឹមត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប



**មាតិកា**


- សេចក្តីបំភ្លឺរបស់អ្នកនាំពាក្យ គ.ជ.ប ......................................................ទំព័រទី ២
- ការផ្សព្វផ្សាយអំពីបណ្តឹងនៅក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ.......................ទំព័រទី ៦
- សវនាការដោះស្រាយលើបណ្តឹងពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង..ទីព័រទី ៩
- ក្រុមប្រឹក្សាធម្មនុញ្ញបានតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប .......................ទំព័រទី ១៣
- មជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប ជម្រុញការបញ្ចូលទិន្នន័យ..............................ទំព័រទី ១៤



necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ 002/11 គ.ជ.ប/អ.ន.ព

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែវិច្ឆិកា ឆ្នាំ២០១១

## សេចក្តីបំភ្លឺរបស់អ្នកនាំពាក្យ គ.ជ.ប ចំពោះការលើកឡើងមិនត្រឹមត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាល មួយចំនួន ពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ នេះ ជាទូទៅបានប្រព្រឹត្តទៅល្អ ទោះបីជារាជធានី ខេត្តភាគច្រើនបានជួបគ្រោះធម្មជាតិទឹកជំនន់ដោយភ្លៀង និងទឹកទន្លេមេគង្គក៏ដោយ ។ លទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះ បង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋ ៩១៥.១៧៨នាក់ បានមកចុះឈ្មោះបោះឆ្នោត ឈ្មោះអ្នកបោះឆ្នោត ២៨៩.០៩៥នាក់ត្រូវបានរាយការណ៍ ដើម្បីលុបចេញពីបញ្ជីបោះឆ្នោត លើចំនួនចាំទុកស្មានអ្នកត្រូវចុះឈ្មោះបោះឆ្នោត ៤៧៦.០៣៧នាក់ និងឈ្មោះត្រូវលុប ១៤៨.២៥០នាក់ និងមានអ្នកបោះឆ្នោតចំនួន ១៣៦.៧៧៦នាក់ បានសុំកែតម្រូវឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។ បន្ថែមលើនេះទៀត បើប្រៀបធៀបនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅឆ្នាំដែលមានរៀបចំការបោះឆ្នោតជាសកលមុនៗ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំនេះ មានបណ្តឹងតិចតួចបំផុត ទាំងនៅពេលចុះឈ្មោះបោះឆ្នោត និងពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ទាំងនៅក្រុមប្រឹក្សាឃុំ សង្កាត់ និងនៅ គ.ជ.ប ។

ទោះយ៉ាងនេះក៏ដោយ ថ្មីៗនេះមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានដាក់អ្នកសង្កេតការណ៍របស់ខ្លួននៅឃុំ សង្កាត់តែជាង ៣០០ ប៉ុណ្ណោះ បានចេញរបាយការណ៍ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១នេះ ដោយបានលើកឡើងនូវចំណុចអវិជ្ជមានមួយចំនួនដែលប្រាសចាកពីការពិត ។ ពិតណាស់ អង្គការ និងអ្នកសង្កេតការណ៍បោះឆ្នោតមានសិទ្ធិចេញរបាយការណ៍របស់ខ្លួន ប៉ុន្តែ គ.ជ.ប មានកាតព្វកិច្ចត្រូវធ្វើការបកស្រាយបំភ្លឺ ដើម្បីឱ្យសាធារណជនបានជ្រាបពីការពិត ។

អ្នកនាំពាក្យ គ.ជ.ប សូមធ្វើការបកស្រាយបំភ្លឺជូនសាធារណជនជ្រាបនូវចំណុចមួយចំនួនដូចខាងក្រោម ៖

១- ការលើកឡើងអំពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតថាបាន ១៥.០០០នាក់ ក្នុងមួយថ្ងៃ ដែលគិតថា ជាចំនួនច្រើនហួសហេតុនោះ តាមពិតចំនួននេះនៅតិចបើប្រៀបធៀបនឹងលទ្ធផលដូចខាងលើ ដែលរួមទាំងការលុប



ឈ្មោះ និងកែតម្រូវឈ្មោះអ្នកបោះឆ្នោត ។ តាមតួលេខលើកឡើងនេះ បើបែងចែកជាមួយនឹងឃុំ សង្កាត់ទាំង ១.៦២១ ឃើញថា ជាមធ្យមក្នុងមួយថ្ងៃ ស្មៀនឃុំ សង្កាត់នីមួយៗ ចុះឈ្មោះអ្នកបោះឆ្នោតបានតែ ១២នាក់ ប៉ុណ្ណោះ ។ ចំពោះលទ្ធផលបណ្ដោះអាសន្នសរុបនៃការចុះឈ្មោះបោះឆ្នោត ដែលមានចំនួនលើសពីចំនួនប៉ាន់ស្មានច្រើននោះ គឺដោយសារមូលហេតុដូចខាងក្រោម ÷

- ការកើនឡើងនៃការផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយរបស់ប្រជាពលរដ្ឋ ដើម្បីស្វែងរកការងារធ្វើដោយពុំបានចុះបញ្ជីស្នាក់នៅ ។
- ការប៉ះទង្គិចដោយអាវុធនៅព្រំដែនកម្ពុជា ថៃ នៅមុនពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលបន្សល់នូវប្រជាពលរដ្ឋភៀសសឹក និងការចល័តកងទ័ព ។
- ការផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោតឆ្នាំនេះមានភាពទូលំទូលាយល្អ បន្ថែមលើនេះទៀត រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់មានរយៈពេលវែងជាងមុន ។

២- ករណីដែលលើកឡើងថា មានការចុះឈ្មោះអ្នកបោះឆ្នោត ដោយសាមីខ្លួនមិនចាំបាច់មកបង្ហាញខ្លួន ឬគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ។ តាមការស្រាវជ្រាវរបស់ គ.ជ.ប ពុំមានករណីបែបនេះទេ ព្រោះថា ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមឃុំ សង្កាត់ទាំង **១.៦២១**ឃុំ សង្កាត់ ទូទាំងប្រទេស ប្រព្រឹត្តទៅដោយតម្លាភាព និងក្រោមការសង្កេតមើលពីភ្នាក់ងារគណបក្សនយោបាយចំនួន **១០.០៩១**នាក់ (គិតទាំងពេញសិទ្ធិ និងបម្រុង) ។ ចំពោះបណ្ដឹងមួយករណីរបស់គណបក្សនយោបាយ ពាក់ព័ន្ធនឹងរឿងហេតុខាងលើ គ.ជ.ប បានចុះទៅពិនិត្យស្រាវជ្រាវ និងបានរកឃើញថា ពុំមានករណីនោះកើតឡើងឡើយ ។

៣- ករណីចោទប្រកាន់ស្មៀនឃុំ សង្កាត់ ថា មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាពដើម្បីចុះឈ្មោះបោះឆ្នោត គឺជាការចោទប្រកាន់ខុសពីការពិត ។ ពីព្រោះ តាមការចុះពិនិត្យស្រាវជ្រាវជាក់ស្ដែងដល់ទីកន្លែង ប្រការដែលស្មៀនឃុំ សង្កាត់ មួយចំនួនបដិសេធការសុំចុះឈ្មោះបោះឆ្នោតដោយសារតែ ÷

- អ្នកសុំចុះឈ្មោះខ្លះប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពសម័យរដ្ឋកម្ពុជា
- អ្នកសុំចុះឈ្មោះខ្លះប្រើប្រាស់ប័ណ្ណបោះឆ្នោតអ៊ុនតាក់
- អ្នកសុំចុះឈ្មោះខ្លះប្រើប្រាស់អត្តសញ្ញាណប័ណ្ណច្បាប់ថតចម្លង ។

ស្មៀនឃុំ សង្កាត់មិនអាចចុះឈ្មោះអ្នកបោះឆ្នោត ដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណ ខាងលើនេះបានទេ ហើយស្មៀនបានណែនាំអ្នកទាំងនោះ ឱ្យរកឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

៤- ជាទូទៅការិយាល័យចុះឈ្មោះបោះឆ្នោត មានទីតាំងនៅសាលាឃុំ សង្កាត់ ដែលឃុំ សង្កាត់ខ្លះមានប៉ុស្ដិ៍នគរបាល

នៅក្បែរ ឬអាគារជាមួយគ្នាតែម្តង ហើយវត្តមានរបស់នគរបាលមូលដ្ឋាននៅទីនោះ គឺជាប្រក្រតីភាពការងារដែលមានចរិតជាខ្សែសង្វាក់ និងចំណងទាក់ទងរវាងសាលាឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ពុំមានរបាយការណ៍អំពីការគំរាមកំហែងណាមួយឡើយ ។ ដូចនេះ ការលើកឡើងក្នុងរបាយការណ៍ អំពីវត្តមានរបស់នគរបាលនៅក្បែរការិយាល័យចុះឈ្មោះបោះឆ្នោតថា ជាការគំរាមកំហែងនោះ គ្រាន់តែជាការបំពុលបរិយាកាសប៉ុណ្ណោះ ។

៥- ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ អាចធ្វើសកម្មភាពរបស់ខ្លួនបានតាមច្បាប់ស្តីពីគណបក្សនយោបាយ ។ គ្រប់សកម្មភាពរបស់គណបក្សនយោបាយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គ.ជ.ប ទេ។ នៅក្នុងអំឡុងពេលនេះ ពុំមានព័ត៌មាន និងបណ្តឹងអំពីយុទ្ធនាការឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយឡើយ ។ ម្យ៉ាងទៀត មុននឹងលើកយកចំណុចនេះមកផ្សព្វផ្សាយជាសាធារណៈ គេគួរយល់ឱ្យបានច្បាស់អំពីនិយមន័យ ខ្លឹមសារ និងរូបភាពនៃយុទ្ធនាការឃោសនាបោះឆ្នោត ។

៦- ចំពោះករណីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន នៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គ.ជ.ប ទេ ។ គ.ជ.ប សូមអរគុណដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីព័ត៌មាន និងការអប់រំផ្សព្វផ្សាយ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ដោយសារលទ្ធផលនៃការផ្សព្វផ្សាយនេះបានធ្វើឱ្យចំនួនអ្នកចុះឈ្មោះបោះឆ្នោតមានចំនួនច្រើនលើសលុប ។ ប៉ុន្តែក៏មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមិនបានបំពេញភារកិច្ចជួយអប់រំផ្សព្វផ្សាយដល់សាធារណជនទេ ។

៧- ការលើកឡើងថា ប្រជាពលរដ្ឋនៅអន្លង់វែង ខេត្តឧត្តរមានជ័យ ចំនួន ១០០នាក់ មិនត្រូវបានចុះឈ្មោះបោះឆ្នោតឱ្យ ការពិតប្រជាពរដ្ឋទាំងនោះត្រូវបានស្មៀនឃុំជួយសម្រួលដោះស្រាយ ចុះឈ្មោះបោះឆ្នោតឱ្យទាំងអស់តាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ។ ប៉ុន្តែក្នុងរបាយការណ៍របស់អង្គការ ដែលចេញផ្សាយកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ នៅតែលើកយកបញ្ហានេះមកផ្សព្វផ្សាយខុសពីការពិតជាក់ស្តែង។

៨- ការដោះស្រាយបណ្តឹងទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គ.ជ.ប ពិនិត្យ និងដោះស្រាយដោយចំហរ តាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដែលត្រូវបានធ្វើការប្រជុំផ្សព្វផ្សាយ និងរៀនសូត្របណ្តុះបណ្តាលដល់មន្ត្រីបោះឆ្នោត និងដោយបានអញ្ជើញតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមផងដែរ ហើយការដោះស្រាយនេះ អនុវត្តតាមឯកសារបញ្ជាក់លក្ខខណ្ឌទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត ÷

១- បញ្ជាក់អត្តសញ្ញាណ



២- សញ្ជាតិខ្មែរ

៣- អាយុ ១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត (សម្រាប់ឆ្នាំដែលមានការបោះឆ្នោត)

៤- ទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត

- ការធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត បានធ្វើស្រប នឹងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាំងពីឆ្នាំ២០០២ ។ ជាលទ្ធផលក្រុមប្រឹក្សាឃុំ សង្កាត់ខិតខំយកចិត្តទុកដាក់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងទទួលបានលទ្ធផលល្អ ។ លទ្ធផលនៃការធ្វើសវនកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកន្លងមក ក៏បានបង្ហាញតួលេខល្អប្រសើរជាសក្ខីភាពផងដែរ ។
- នៅពិភពលោក ការចុះឈ្មោះបោះឆ្នោតមាន ៣ របៀប ។ ដំណាក់កាលទី១ គេតែងអនុវត្តការ ចុះឈ្មោះម្តងបោះឆ្នោតម្តង ដែលកន្លងមកប្រទេសកម្ពុជាយើងបានធ្វើរបៀបនេះនៅសម័យអ៊ុនតាក់ និងកាលពីការបោះឆ្នោតជ្រើសតាំងសមាជិកសភា អាណត្តិទី២ ឆ្នាំ១៩៩៨ ។ ដំណាក់កាលទី២ គឺដូចបច្ចុប្បន្ននេះ យើងកំពុងអនុវត្តការចុះឈ្មោះតាមរបៀបការចុះឈ្មោះដោយធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតជារៀងរាល់ឆ្នាំ និងរក្សាទុកសៀវភៅបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ជាអចិន្ត្រៃយ៍ ។ ឯការចុះឈ្មោះជាអចិន្ត្រៃយ៍ ដោយផ្អែកលើអត្រានុគោលដ្ឋាន ជាដំណាក់កាលទី៣ ដូចដែលអង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងជាអនុសាសន៍នោះ គ.ជ.ប ក៏ចង់បានការធ្វើរបៀបនេះដែរ ប៉ុន្តែសភាពការណ៍នៃប្រទេសយើងសព្វថ្ងៃ ពុំទាន់មានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើការចុះឈ្មោះរបៀបនេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមស្វាគមន៍ចំពោះការលើកឡើងនូវបញ្ហាផ្សេងៗ និងអនុសាសន៍របស់គណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោត ទាក់ទងទៅនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក៏ដូចជាការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតនៅប្រទេសកម្ពុជា ប្រព្រឹត្តទៅប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។ ប៉ុន្តែ គ.ជ.ប ក៏សូមស្រាយបំភ្លឺជូនសាធារណជនឱ្យបានជ្រាបដែរ ចំពោះការលើកឡើងទាំងឡាយណាដែលប្រាសចាកពីការពិត ដើម្បីជៀសវាងការយល់ច្រឡំ ដែលនាំឱ្យរាំងស្ទះដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត។

គ.ជ.ប ស្វាគមន៍ បន្តការគាំទ្រ និងបង្កលក្ខណៈដល់គ្រប់ការធ្វើសវនកម្មបញ្ជីបោះឆ្នោត ។





# ការផ្សព្វផ្សាយអំពីបណ្តឹងនៅក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១





*សន្និសីទសារព័ត៌មាន កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១*

បណ្តឹងទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដែលប្តឹងដោយគណបក្សនយោបាយ និងប្រជាពលរដ្ឋ ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ប្រកាសផ្សព្វផ្សាយដល់គណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោត អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ នៅក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១។

លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាននោះថា ពាក្យបណ្តឹងសរុបចំនួន ៦១បណ្តឹង ត្រូវបានប្តឹងដោយតំណាងគណបក្សនយោបាយ និងប្រជាពលរដ្ឋនៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១។ បណ្តឹងទាំងនោះចែកចេញជា ២ដំណាក់កាល គឺដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ឆ្នាំ២០១១។

### ១-ដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១

ពាក្យបណ្តឹងដែលត្រូវបានប្តឹងនៅថ្នាក់ក្រុមប្រឹក្សា





ឃុំ សង្កាត់ សរុបមានចំនួន ១២បណ្តឹង ក្នុងនោះនៅរាជធានីភ្នំពេញ ចំនួន ០៨បណ្តឹង ខេត្តកណ្តាល ចំនួន ០២បណ្តឹង និងខេត្តសៀមរាប ចំនួន ០២បណ្តឹង។ លទ្ធផលនៃការដោះស្រាយនៅថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់មានដូចខាងក្រោម ៖

-ប្រជុំសម្រេចយល់ព្រមតាមពាក្យបណ្តឹង ចំនួន ០៥បណ្តឹង។

-ប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹង ចំនួន ០១បណ្តឹង។

-ចេញលិខិតជូនដំណឹងបដិសេធលើពាក្យបណ្តឹង ចំនួន ០៣បណ្តឹង។

-ធ្វើការផ្សះផ្សាសះជា ចំនួន ០១បណ្តឹង។

-ធ្វើការផ្សះផ្សាមិនសះជា ចំនួន ០១បណ្តឹង។

-សាមីដើមបណ្តឹងដកពាក្យបណ្តឹងវិញ ចំនួន ០១បណ្តឹង។

ពាក្យបណ្តឹងដែលត្រូវបានប្តឹងនៅ គ.ជ.ប សរុបមានចំនួន ១០បណ្តឹង ក្នុងនោះពាក្យបណ្តឹងមកពីរាជធានីភ្នំពេញ មានចំនួន ០៥បណ្តឹង ខេត្តកណ្តាល មានចំនួន ០៤បណ្តឹង និងខេត្តសៀមរាប មានចំនួន ០១បណ្តឹង។



លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប ថ្លែងទៅកាន់អ្នកសារព័ត៌មាន

ពាក្យបណ្តឹងទាំងនោះមាន ០៨បណ្តឹង ត្រូវបានប្តឹងផ្ទាល់នៅ គ.ជ.ប និងមាន ០២បណ្តឹង ត្រូវបានដើមបណ្តឹងបន្តប្តឹងពីក្រុមប្រឹក្សាឃុំ សង្កាត់មក គ.ជ.ប។ លទ្ធផលនៃការដោះស្រាយបណ្តឹងនៅ គ.ជ.ប មានដូចខាងក្រោម ៖

-ចេញលិខិតជូនដំណឹងយល់ព្រមតាមពាក្យបណ្តឹង ចំនួន ០៣បណ្តឹង។

-ចេញលិខិតជូនដំណឹងបដិសេធលើពាក្យបណ្តឹង ចំនួន ០៥បណ្តឹង។

-ដើមបណ្តឹងដកពាក្យបណ្តឹងវិញ ចំនួន ០២បណ្តឹង។

នៅក្នុងដំណាក់កាលនេះដែរ មានពាក្យបណ្តឹង ចំនួន ០២បណ្តឹង ត្រូវបានដាក់បន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ជាលទ្ធផលក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើលិខិតជូនដំណឹងបដិសេធ ព្រោះបណ្តឹងទាំងពីរនេះមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ពាក្យបណ្តឹងទាំងអស់ខាងលើនេះ ត្រូវបានដាក់ប្តឹងដោយគណបក្សសម រង្ស៊ី ចំនួន ១៨បណ្តឹង និងប្រជាពលរដ្ឋចំនួន ០២បណ្តឹង។

### ២-ដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១១

ពាក្យបណ្តឹងដែលត្រូវបានប្តឹងនៅក្រុមប្រឹក្សាឃុំ សង្កាត់ សរុបមានចំនួន ៤១បណ្តឹង ក្នុងនោះនៅរាជធានីភ្នំពេញ ចំនួន ០៧បណ្តឹង ខេត្តកណ្តាល ចំនួន ១១បណ្តឹង ខេត្តព្រៃវែង ចំនួន ២០បណ្តឹង ខេត្តសៀមរាប ចំនួន ០២បណ្តឹង និងខេត្តស្ទឹងត្រែង ចំនួន ០១បណ្តឹង។ លទ្ធផលនៃការដោះស្រាយបណ្តឹងនៅថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់មានដូចខាងក្រោម ៖

-ប្រជុំសម្រេចយល់ព្រមតាមពាក្យបណ្តឹង ចំនួន ០៥បណ្តឹង។





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១





*តំណាងគណបក្សនយោបាយសួរសំណួរទៅកាន់វាគ្មិនក្នុងអង្គសន្និសីទសារព័ត៌មាន*

-ប្រជុំសម្រេចបដិសេធលើពាក្យបណ្ដឹង ចំនួន ១៨បណ្ដឹង។

-ប្រជុំសម្រេចយល់ព្រមមួយផ្នែកតាមពាក្យបណ្ដឹង និងបដិសេធមួយផ្នែកលើពាក្យបណ្ដឹង ចំនួន ១៥បណ្ដឹង។

-ចេញលិខិតជូនដំណឹងបដិសេធលើពាក្យបណ្ដឹង ចំនួន ០២បណ្ដឹង។

-សាមីដើមបណ្ដឹងដកពាក្យបណ្ដឹងវិញ ចំនួន ០១បណ្ដឹង។

ពាក្យបណ្ដឹងដែលត្រូវបានប្ដឹងមក គ.ជ.ប សរុបមានចំនួន ៣២បណ្ដឹង ក្នុងនោះមានពាក្យបណ្ដឹងមកពីរាជធានីភ្នំពេញ ចំនួន ០៧បណ្ដឹង ខេត្តកណ្ដាល ចំនួន ០៩បណ្ដឹង ខេត្តព្រៃវែង ចំនួន ១៥បណ្ដឹង និងខេត្តសៀមរាប ចំនួន ០១បណ្ដឹង។ លទ្ធផលនៃការដោះស្រាយនៅថ្នាក់ គ.ជ.ប មានដូចខាងក្រោម ៖

-បើកសវនាការយល់ព្រមតាមពាក្យបណ្ដឹង ចំនួន ០១បណ្ដឹង។

-បើកសវនាការបដិសេធលើពាក្យបណ្ដឹង ចំនួន ០១បណ្ដឹង។

-បើកសវនាការយល់ព្រមមួយផ្នែកតាមពាក្យបណ្ដឹង និងបដិសេធមួយផ្នែកលើពាក្យបណ្ដឹង ចំនួន ០១បណ្ដឹង។

-ចេញលិខិតជូនដំណឹងបដិសេធលើពាក្យបណ្ដឹង ចំនួន ១២បណ្ដឹង។

-ចេញលិខិតជូនដំណឹងយល់ព្រមមួយផ្នែកតាមពាក្យបណ្ដឹង និងបដិសេធមួយផ្នែកលើពាក្យបណ្ដឹង ចំនួន ១៥បណ្ដឹង។

-ចារបដិសេធលើពាក្យបណ្ដឹង ចំនួន ០២បណ្ដឹង។

នៅក្នុងដំណាក់កាលនេះដែរ មានពាក្យបណ្ដឹង ចំនួន ០២បណ្ដឹង ត្រូវបានប្ដឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ជាលទ្ធផលក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើលិខិតជូនដំណឹងបដិសេធលើពាក្យបណ្ដឹងចំនួន ០១បណ្ដឹង ព្រោះមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និង ០១បណ្ដឹង ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញបើកសវនាការដោះស្រាយ ដោយបដិសេធលើពាក្យបណ្ដឹង។

នៅក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ពាក្យបណ្ដឹងដែលត្រូវបានដាក់ប្ដឹងដោយគណបក្សសម រង្ស៊ី មានចំនួន ៣៧បណ្ដឹង គណបក្សប្រជាជនកម្ពុជា មានចំនួន ០១បណ្ដឹង និងប្រជាពលរដ្ឋ មានចំនួន ០៣បណ្ដឹង៕



# សវនាការដោះស្រាយលើបណ្តឹងពាក់ព័ន្ធនឹងការបិទផ្សាយ បញ្ជីបោះឆ្នោតដំបូង នៅ គ.ជ.ប



*ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)*

នៅក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ មានបណ្តឹងចំនួន៣ ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បើកសវនាការជាសាធារណៈដាច់ដោយឡែកពីគ្នា។

**ការបើកសវនាការលើបណ្តឹងទី១ ៖** បណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី បានប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំកំពង់លួង មិនព្រមលុបឈ្មោះអ្នកបោះឆ្នោតចំនួន ៥៨នាក់ ចេញពីបញ្ជីបោះឆ្នោតឆ្នាំ២០១១ ដោយចោទថា អ្នកទាំងនោះជាជនបរទេស។ ហើយក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប បានលើកយកបណ្តឹងនេះមកបើកសវនាការជាសាធារណៈ កាលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១។ ក្រោយពីសាកសួរដើមបណ្តឹង និងចុងចម្លើយ រួមទាំងសាក្សីផង អស់រយៈពេលប្រមាណ ៣ម៉ោងរួចមក ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប បានសម្រេចលុបឈ្មោះអ្នកបោះឆ្នោតចំនួន ១៩នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង និងរក្សាទុកឈ្មោះអ្នកបោះឆ្នោតចំនួន ៣៩នាក់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៅឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល។

**ការបើកសវនាការលើបណ្តឹងទី២ ៖** បណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី ដែលបានប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ដែលបានរក្សាទុកឈ្មោះជនបរទេសចំនួន ១៤នាក់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃឃុំនេះ។ បន្ទាប់ពីលើកយកសំណុំរឿងនេះមកបើកសវនាការជាសាធារណៈ អស់រយៈពេលប្រមាណ ២ម៉ោង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប បានសម្រេច





# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



*ឯកឧត្តម អ៊ឹម សួស្តី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប អានសេចក្តីសម្រេចសវនាការ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១*

តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំលើកដែក ដោយរក្សាទុកឈ្មោះអ្នកបោះឆ្នោតចំនួន ១៤នាក់ ក្នុងបញ្ជីបោះឆ្នោត។

ការរក្សាទុកឈ្មោះអ្នកទាំងនោះនៅក្នុងបញ្ជីបោះឆ្នោតដំបូងនៅឃុំលើកដែកនោះ ដោយនៅក្នុងសវនាការ លោក រស់ សួរ ដែលជាដើមបណ្តឹង និងជាតំណាងគណបក្សសម រង្ស៊ី មិនបានបង្ហាញភស្តុតាងបញ្ជាក់ច្បាស់លាស់ណាមួយឡើយ ដោយគ្រាន់តែសម្អាងថា អ្នកទាំង ១៤នាក់ ជាជនបរទេស។

តាមការបំភ្លឺរបស់លោក សុខ គឹមលាង មេឃុំលើកដែក នៅក្នុងសវនាការ បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំលើកដែក សម្រេចមិនលុបឈ្មោះអ្នកបោះឆ្នោតទាំង ១៤នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង ដោយហេតុថា អ្នកទាំងនោះមានទីលំនៅបច្ចុប្បន្ននៅក្នុងឃុំលើកដែក និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតតាំងពីឆ្នាំ២០០៣។ ម្យ៉ាងវិញទៀត លោក ម៉ា ប៊ុនហ៊ី នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំលើកដែក បានបញ្ជាក់ថា នៅក្នុងឃុំលើកដែក មានតែពីរគ្រួសារប៉ុណ្ណោះដែលមានឈ្មោះនៅក្នុងបញ្ជីគ្រប់គ្រងជនអន្តោប្រវេសន៍ ចំណែកឯឈ្មោះអ្នកបោះឆ្នោតទាំង ១៤នាក់ ដែលគណបក្សសម រង្ស៊ី បានប្តឹងនេះពុំមានឈ្មោះក្នុងបញ្ជីគ្រប់គ្រងជនអន្តោប្រវេសន៍ឃុំលើកដែកឡើយ។



*លោក រស់ សួរ តំណាងគណបក្សសម រង្ស៊ី*

**ការបើកសវនាការលើបណ្តឹងទី៣ ៖** បណ្តឹងរបស់តំណាងគណបក្សប្រជាជនកម្ពុជា បានប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលបានសម្រេចមិនលុបឈ្មោះអ្នកបោះឆ្នោតតាមពាក្យបណ្តឹង។ បណ្តឹងនេះត្រូវបាន គ.ជ.ប បើកសវនាការដោះស្រាយ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១ ជាលទ្ធផល ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប បានសម្រេចបដិសេធសេចក្តីសម្រេចលេខ០២ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសង្កាត់បឹងសាឡាង ចោលជាអាសាបង់ និងសម្រេចលុបឈ្មោះអ្នកបោះឆ្នោតចំនួន ៥៦៤នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅសង្កាត់បឹងសាឡាង។

នៅក្នុងសវនាការ លោក សួង សុផល មេធាវី

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១







*ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ស្តាប់ចម្លើយសាក្សីរបស់លោក សួង សុផល មេធាវីតំណាងដើមបណ្តឹង ក្នុងសវនាការ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១*

តំណាងដើមបណ្តឹងបានឆ្លើយបញ្ជាក់ថា ខ្លួនប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសង្កាត់បឹងសាឡាង ដែលមិនព្រមលុបឈ្មោះអ្នកបោះឆ្នោតចំនួន ៥៦៤នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង ហើយលោកមានភស្តុតាងជាឯកសារ និងសាក្សីបញ្ជាក់ថា ឈ្មោះអ្នកបោះឆ្នោតទាំងនោះ មានអ្នកស្លាប់ចំនួន ១៦នាក់ និងគ្មានទីលំនៅក្នុងសង្កាត់ចំនួន ៥៤៨នាក់។ លោក សួង សុផល បានថ្លែងថា ការស្នើសុំលុបឈ្មោះនេះ គឺធ្វើឡើងស្របតាមច្បាប់ និងបទបញ្ញា និងនីតិវិធី គ.ជ.ប ដើម្បីសម្អាតបញ្ជីបោះឆ្នោតឱ្យបានត្រឹមត្រូវ។

នៅក្នុងសវនាការ លោក ទូច ម៉េងស្រ៊ាង ប្រធានក្រុមប្រឹក្សាសង្កាត់បឹងសាឡាង បានអះអាងផ្ទាល់មាត់ថា ការរក្សាទុកឈ្មោះអ្នកបោះឆ្នោតចំនួន ៥៦៤នាក់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនេះ ដោយសារដើមបណ្តឹងពុំភ្ជាប់មកជាមួយនូវភស្តុតាងឡើយ មានតែបញ្ជីឈ្មោះ



*លោក ទូច ម៉េងស្រ៊ាង ប្រធានក្រុមប្រឹក្សាសង្កាត់បឹងសាឡាង*



*លោក សួង សុផល មេធាវីតំណាងដើមបណ្តឹង*







*ក្រុមប្រឹក្សាជំនុំជម្រះស្តាប់សាក្សីបំភ្លឺក្នុងសវនាការ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១*

សុំលុប។ ហើយប្រសិនបើក្រុមប្រឹក្សាសង្កាត់សម្រេចលុបឈ្មោះអ្នកទាំងនោះចេញ គឺធ្វើឱ្យបាត់សិទ្ធិអ្នកបោះឆ្នោតពីព្រោះគាត់(ទូច ម៉េងស្រ៊ាង) យល់ថា អ្នកទាំងនោះគ្រាន់តែទៅរកស៊ីនៅទីឆ្ងាយ ហើយអាចវិលមកបោះឆ្នោតវិញនៅពេលបោះឆ្នោត។



*មេភូមិ១ សង្កាត់បឹងសាឡាង សាក្សី*

នៅក្នុងសវនាការ លោក សួង សុផល មានឯកសារបញ្ជាក់ មានសាក្សី ១៥នាក់ ដែលជាប្រជាពលរដ្ឋ មេភូមិ និងមេប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់បឹងសាឡាង ដែលអះអាងថា អ្នកទាំង ៥៦៤នាក់នោះ មាន ១៦នាក់ ស្លាប់ និង ៥៤៨នាក់ គ្មានទីលំនៅពិតប្រាកដក្នុងសង្កាត់បឹងសាឡាងទេ៕





*សាក្សីរបស់លោក សួង សុផល ដែលជាមេប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់បឹងសាឡាង មេភូមិ និងប្រជាពលរដ្ឋ*



# ក្រុមប្រឹក្សាធម្មនុញ្ញ បានតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប ដោយរក្សាទុកឈ្មោះអ្នកបោះឆ្នោត ចំនួន ៣៩នាក់ នៅឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល





*ឯកឧត្តម ឯម សូផាត (រូបឆ្វេង) ឯកឧត្តម ម៉ៅ សុភារិទ្ធ (រូបកណ្តាល) សមាជិក គ.ជ.ប និង លោក កែ រិទ្ធ នៅក្នុងសវនាការក្រុមប្រឹក្សាធម្មនុញ្ញ*

ការដាក់/ទទួល និងដោះស្រាយបណ្តឹងទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ មាន ៣ថ្នាក់ **ទី១** គឺនៅថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់ **ទី២** នៅថ្នាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និង**ទី៣** នៅថ្នាក់ក្រុមប្រឹក្សាធម្មនុញ្ញ។

តាមវិបសាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (www.ccc.gov.kh) បានឱ្យដឹងថា "ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ សម្រាប់ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា"។ ការដោះស្រាយបណ្តឹងទាក់ទងនឹងការបោះឆ្នោតនៅថ្នាក់ក្រុមប្រឹក្សាធម្មនុញ្ញ ជាការដោះស្រាយចុងក្រោយ និងបិទផ្លូវតវ៉ា។ នៅក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១ ស្ថាប័ននេះបានទទួលពាក្យបណ្តឹងចំនួន ៤ ដែលបានដាក់ពាក្យបណ្តឹង ដោយតំណាងគណបក្សនយោបាយ។ ហើយក្នុងចំណោមបណ្តឹងទាំងបួននេះមាន ១បណ្តឹង ត្រូវបានបើកសវនាការជាសាធារណៈ និង ៣បណ្តឹងទៀត ត្រូវបានធ្វើលិខិតជូនដំណឹងបដិសេធទៅដើមបណ្តឹងវិញ។

បណ្តឹងដែលត្រូវបានបើកសវនាការ ជាបណ្តឹងរបស់គណបក្សសម រង្ស៊ី ដែលមានលោក រស់ សួរ ជាតំណាងដើមបណ្តឹង ដោយលោកបានប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានរក្សាទុកឈ្មោះអ្នកបោះឆ្នោតចំនួន ៣៩នាក់ តទៅទំព័រទី 15





## មជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប ជម្រុញការបញ្ចូលទិន្នន័យឱ្យចប់មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

មជ្ឈមណ្ឌលកុំព្យូទ័រនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានជម្រុញការងាររបស់ខ្លួនយ៉ាងសកម្មក្នុងការបញ្ចូលទិន្នន័យ ការកែតម្រូវទិន្នន័យ ការលុបឈ្មោះអ្នកស្លាប់ អ្នកផ្លាស់ប្ដូរទីលំនៅ និងឈ្មោះស្ទួនចេញពីបញ្ជីបោះឆ្នោត ទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីផលិតបញ្ជីបោះឆ្នោតដាក់ជូន គ.ជ.ប ផ្ដល់សុពលភាព និងការប្រកាសផ្សាយជាផ្លូវការនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។



*លោក យឿង កុសល ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប*

លោក យឿង កុសល ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រនៃនាយកដ្ឋានប្រត្តិបត្តការ គ.ជ.ប បានមានប្រសាសន៍ថា បន្ទាប់ពីបញ្ចប់ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង មជ្ឈមណ្ឌលមានសកម្មភាពមមាញឹកណាស់ ព្រោះត្រូវទទួលកញ្ចប់សម្ភារចុះឈ្មោះបោះឆ្នោតពីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត(លធ/ខប)ទាំង២៤ និងធ្វើការផ្ទៀងផ្ទាត់របាយការណ៍ ជាពិសេសទៅទៀតគឺជម្រុញការផលិតបញ្ជីបោះឆ្នោតឱ្យទាន់តាមប្រតិទិន។

ទាក់ទងនឹងសកម្មភាពការងារនេះ លោក យឿង កុសល បានឱ្យដឹងថា រាល់កញ្ចប់ដែលបានបញ្ជូនពីលធ/ខប ទាំង២៤ មជ្ឈមណ្ឌលបានបញ្ជូនទៅការិយាល័យទទួល បញ្ជូន និងស្ដុកឯកសារ ហើយការីទទួល បញ្ជូន និងស្ដុកឯកសារ ត្រូវពិនិត្យមើលឈ្មោះឆ្វូតលុបដែលស្មៀនឃុំ សង្កាត់បានឆ្វូតនៅក្នុងបញ្ជីបោះឆ្នោត រួចផ្ទៀងផ្ទាត់ជាមួយនឹងឯកសារយោង រួមមាន សំបុត្រមរណភាព លិខិតបញ្ជាក់ផ្លាស់ទីលំនៅ និងទម្រង់សុំលុបឈ្មោះស្ទួន។ បន្ទាប់ពីពិនិត្យផ្ទៀងផ្ទាត់ចប់រួចរាល់ ផ្នែកនេះបញ្ជូនកញ្ចប់ទៅផ្នែកកំណត់ចំនួនអ្នកបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រ ផ្នែកការីលុបទិន្នន័យ។ កញ្ចប់ទិន្នន័យអ្នកបោះឆ្នោតនៃការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវលុបដោយការីលុបទិន្នន័យចំនួន២ក្រុម(Double Entry)។ ក្រុមទី១ ត្រូវលុបឈ្មោះអ្នកបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រ ដោយផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតជាមួយនឹងទិន្នន័យអ្នកបោះឆ្នោតដែលឆ្វូតលុបនៅក្នុងបញ្ជីបោះឆ្នោត និងឯកសារយោង។ បន្ទាប់ពីក្រុមទី១លុបរួចហើយ ត្រូវបញ្ជូនកញ្ចប់ដែលលុបរួចនោះ ទៅក្រុមលុបទី២។ ក្រុមទី២មានតួនាទីលុបឈ្មោះអ្នកបោះឆ្នោតដូចក្រុមទី១ដែរ បើសិនក្រុមទី២លុបឈ្មោះអ្នកបោះឆ្នោតត្រូវនឹងឈ្មោះអ្នកបោះឆ្នោត(រួមទាំងទិន្នន័យផ្សេងទៀត) ដែលក្រុមទី១បានលុបដែរនោះ ប្រព័ន្ធកុំព្យូទ័រអនុញ្ញាតឱ្យលុបឈ្មោះអ្នកបោះឆ្នោតនោះ ប៉ុន្តែបើក្រុមទី១ និងក្រុមទី២លុបមិនត្រូវគ្នាទេ ប្រព័ន្ធកុំព្យូទ័រនឹងមិនអនុញ្ញាតឱ្យលុបឡើយ។ ការធ្វើរបៀបនេះ គឺដើម្បីធានាឱ្យបានទូវបញ្ជីបោះឆ្នោតមួយល្អ និងត្រឹមត្រូវ។

តទៅទំព័រទី 15

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១១



តមកពីទំព័រទី 13 **ក្រុមប្រឹក្សាធម្មនុញ្ញបានតម្កល់...**

នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៅឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល ដោយចោទថា អ្នកទាំងនោះជាជនបរទេស។

នៅក្នុងអង្គសវនាការកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ លោក រស់ សួរ មិនបានបង្ហាញពីភស្តុតាងណាមួយទេ ដោយគ្រាន់តែបញ្ជាក់ផ្ទាល់មាត់ថា អ្នកទាំងនោះជាជនជាតិវៀតណាម ដែលមករស់នៅតាំងពីឆ្នាំ១៩៩១-១៩៩២ និងខ្លះមករស់នៅឆ្នាំ១៩៨៥ ហើយមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៅឃុំកំពង់លួងតាំងពីឆ្នាំ២០០៣។

ឯកឧត្តម ឯម សូផាត សមាជិក គ.ជ.ប បានមានប្រសាសន៍នៅក្នុងអង្គសវនាការថា នៅក្នុងសវនាការរបស់ គ.ជ.ប លោក រស់ សួរ ពុំបានបង្ហាញភស្តុតាង ឯកសារណាមួយបញ្ជាក់ចំពោះមុខអង្គសវនាការទេ ដោយគ្រាន់តែអះអាងផ្ទាល់មាត់ថា អ្នកទាំងនោះមានសំនៀងភាសានិយាយ ពណ៌សម្បុរ និងឈ្មោះត្រកូលជាជនជាតិវៀតណាម។

ឯកឧត្តម ឯម សូផាត បានបញ្ជាក់ទៀតថា មូលហេតុដែល គ.ជ.ប លុបឈ្មោះចំនួន ១៩នាក់(ស្លាប់៤នាក់ និងគ្មានទីលំនៅក្នុងឃុំ១៥នាក់) និងរក្សាទុកឈ្មោះចំនួន ៣៩នាក់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៅឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្ដាល ដោយសារអ្នកទាំងនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតតាំងពីឆ្នាំ២០០៣មកម្ល៉េះ ហើយតាមការអះអាងរបស់លោកមេប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងលោកប្រធានក្រុមប្រឹក្សាឃុំកំពង់លួង បានបញ្ជាក់នៅក្នុងសវនាការរបស់ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ ថា បច្ចុប្បន្នអ្នកទាំង ៣៩នាក់ ហ្នឹងកំពុងរស់នៅក្នុងឃុំកំពង់លួង ហើយឈ្មោះទាំងនេះក៏ពុំមាននៅក្នុងបញ្ជីគ្រប់គ្រងជនអន្តោប្រវេសន៍ទេ។

ក្រោយពីស្ដាប់ចម្លើយរបស់គូភាគី និងក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញសម្រេចទទួលពាក្យបណ្ដឹង ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ របស់លោក រស់ សួរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ហើយតម្កល់សេចក្ដីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ទុកជាបានការពេញទាំងមូល។ សេចក្ដីសម្រេចនេះបានប្រកាសជាសាធារណៈ ហើយជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា និងមានអនុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច៕

តមកពីទំព័រទី 14 **មជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប...**

លោក យឿង កុសល បានបញ្ជាក់ថា មជ្ឈមណ្ឌលកុំព្យូទ័របញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីបង្កើតជាបញ្ជីបោះឆ្នោត បន្ទាប់មកដាក់ជូន គ.ជ.ប ពិនិត្យដើម្បីផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតនេះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១៕

ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប
អ្នកគ្រប់គ្រង លោក **ម៉ៃ សារី**
ក្រុមនិពន្ធ
លោក ជា សែ
លោក សុខ លាភ
កំណែអក្ខរាវិរុទ្ធ
អ្នកស្រី ទិន សាវត្ថី
អ្នកថតរូប
លោក សាក់ បូរិន
ក្រាហ្វិកកុំព្យូទ័រ
លោក ប៉េង រតនៈ
លោក ចាន់ វិបុល

# សកម្មភាពការងាររបស់មជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប

2011




*សកម្មភាពទទួលកញ្ចប់ទិន្នន័យអ្នកបោះឆ្នោតពីរាជធានី ខេត្តទាំង២៤*







*សកម្មភាពពិនិត្យ និងរៀបចំកញ្ចប់ទិន្នន័យអ្នកបោះឆ្នោត*







*សកម្មភាពបញ្ចូល កែតម្រូវ និងលុបទិន្នន័យអ្នកបោះឆ្នោត*



